ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 02-Nov-2011, 08:55
CMS/CFO: Uch Arun

## អង្គជំនុំជម្រះតុលាការកំពូល

ជូនចំពោះ : គ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២ កាលបរិច្ឆេទ : ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១

ពី: គង់ ស្រ៊ឹម ប្រធានអង្គជំនុំជម្រះតុលាការកំពូល

ចម្លងជូន: ចៅក្រមអង្គជំនុំជម្រះតុលាការកំពូលទាំងអស់ និងផ្នែកគ្រប់គ្រងតុលាការ

កម្មវត្ថុ: វិសោធនកម្មនៃលក្ខខណ្ឌតម្រូវក្នុងការដាក់សេចក្តីចម្លងនៃបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់

អង្គជំនុំជម្រះតុលាការកំពូលដោយយោងទៅលើសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក (អ.វ.ត.ក/០១/២០០៧/វិ.០៧) ត្រង់មាត្រា ៦(៣) ដែលចែងថា “ឯកសារត្រូវដាក់ជាមួយសេចក្តីចម្លងនៃបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ ដែលប្រើប្រាស់ជាឯកសារយោង លើកលែងតែឯកសារយោងមានក្នុងកំរងអត្ថបទច្បាប់របស់ អ.វ.ត.ក មានផ្សាយនៅក្នុងគេហទំព័ររបស់ អ.វ.ត.ក”។

អង្គជំនុំជម្រះតុលាការកំពូល ជូនដំណឹងដល់គ្រប់ភាគីនៃសំណុំរឿង ០០២ ថា ដូចអង្គជំនុំជម្រះសាលាដំបូង ដែរ[១] អង្គជំនុំជម្រះតុលាការកំពូលនឹងអនុញ្ញាតឲ្យភាគីទាំងអស់ មិនចាំបាច់ដាក់សេចក្តីចម្លងនៃបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ដែលបានប្រើប្រាស់ជាឯកសារយោង ដូចជា ករណីយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ និងអត្ថបទនានានៃលិខិតុបករណ៍អន្តរជាតិល្បីៗ ដែលមានជាសាធារណៈរួចហើយ ហើយអង្គជំនុំជម្រះតុលាការកំពូល និងគ្រប់ភាគីទាំងអស់អាចទទួលបានយ៉ាងងាយស្រួល។ ចំពោះឯកសារយោងសំអាងផ្លូវច្បាប់នានា ដែលមិនអាចរកបានដោយងាយស្រួលវិញ ភាគីត្រូវដាក់បញ្ជីឯកសារនៅក្នុងតារាងមូលដ្ឋានសំអាងផ្លូវច្បាប់ស្របតាមសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការយោង ភាគីត្រូវរៀបរាប់បញ្ជីឈ្មោះឯកសារយោង សំអាងផ្លូវច្បាប់ទាំងអស់ទៅក្នុងបញ្ជីតារាងមូលដ្ឋានសំអាងផ្លូវច្បាប់។

---

[១] ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E72, ERN 00658635-00658635 (ភាសាអង់គ្លេស); 00658634-00658634 (ភាសាខ្មែរ)។